# ស៊ែឡក់ ហាល់មែស

## ប និងកូនប្រុសលោកអភិជន



និពន្ធដោយលោក៖ **Author Conan Doyle**

បកប្រែជាខេមរភាសាដោយ៖ ***F***

# វគ្គ ១

# ស៊ែឡក់ ហូលមែសមានភ្ញៀវ

*នៅពេលដែលមានភ្ញៀវមករកស៊ែឡក់ ហូលមែសនៅមហាវិថីប៊ែកឃើរ ពួកគេតែងតែធ្វើនូវរឿងដ៏គួរឲ្យភ្ញាក់ផ្អើលផ្សេងៗ។ ជួនកាលគេយកដៃខ្ទប់មុខរបស់គេ ហើយយំ។ ជួនកាលគេនិយាយហើយនិយាយទៀត ដោយមិនអាចបញ្ឈប់សោះ។ ហើយជួនកាលទៀត គេអង្គុយនៅទីនោះ ហើយមិនស្ដីមួយម៉ាត់សោះ។ ប៉ុន្តែគ្មាននរណាដែលគួរឲ្យភ្ញាក់ផ្អើលជាងវេជ្ជបណ្ឌិតថនីក្រហ្វ ហ៊ុកស៍ថាបលនោះទេ។*

*គាត់គឺជាបុរសខ្ពស់ម្នាក់ ដែលស្លៀកពាក់សមរម្យ ហើយមើលទៅដូចជាមនុស្សសំខាន់។ គាត់បានចូលមកក្នុងបន្ទប់ ដើរសំដៅទៅរកកៅអីដ៏ធំមួយ ហើយភ្លាមនោះក៏ដួលទៅលើវា។ គាត់អង្គុយនៅទីនោះដោយបិទភ្នែករបស់គាត់ មើលទៅដូចជាស្ទេកស្វាំង ហើយមានជម្ងឺ។*

*ខ្ញុំបានរត់ទៅយកទឹកមកឲ្យគាត់។ បន្ទាប់មកខ្ញុំយកកាតាបពេទ្យរបស់ខ្ញុំ ហើយសម្លឹងមើលគាត់យ៉ាងប្រុងប្រយ័ត្ន។*

*"តើគាត់យ៉ាងម៉េចហើយ វ៉ាត់សាន់?" ហូលមែសបានស្រដី។*

"គ្នាគិតថាគាត់មិនអីទេ" ខ្ញុំបាននិយាយ។ "គាត់គ្រាន់តែនឿយហត់ខ្លាំងពេក-ហើយប្រហែលជាឃ្លានខ្លាំងដែរហើយមើលទៅ។

ហូលមែសសម្លឹងមើលទៅក្នុងហោប៉ៅរបស់បុរសម្នាក់នោះ-ហើយរកឃើញសំបុត្ររថភ្លើងមួយពីម៉ាកខ្លិតុន នៅខាងជើងប្រទេសអង់គ្លេស។

"ម៉ាកខ្លិតុន-នៅឆ្ងាយណាស់" ហូលមែសបាននិយាយ។ "វាមិនទាន់ម៉ោងដប់ពីរនៅឡើយទេ អញ្ចឹងគាត់ប្រហែលជាចាកចេញពីផ្ទះនៅម៉ោងប្រាំព្រឹកនេះហើយ។"

ពីរបីនាទីក្រោយមក បុរសនោះចាប់ផ្តើមកម្រើក ហើយភ្នែករបស់គាត់បើកឡើង។ មួយវិនាទីក្រោយមក គាត់ក៏ក្រោកឈរឡើងយ៉ាងរហ័ស។ មុខគាត់ឥលូវឡើងពណ៌ក្រហម ហើយមិនសប្បាយចិត្តឡើយ។

"លោកហូលមែស ខ្ញុំសុំទោស! ខ្ញុំគ្មានហូបបាយហូបទឹកសោះព្រឹកនេះ-នោះគឺជាមូលហេតុដែលធ្វើឲ្យខ្ញុំមានអារម្មណ៍មិនសូវស្រួលខ្លួន ។"

"នៅពេលដែលលោកមានអារម្មណ៍ធូរស្បើយវិញ..." ខ្ញុំបានចាប់ផ្តើមនិយាយ។

"ឥលូវខ្ញុំធូរស្បើយហើយ អរគុណ" ភ្ញៀវរបស់យើងបានស្រដី។ "ហើយខ្ញុំចង់និយាយជាមួយលោកស្ស៊ឺឡក់ ហូលមែសខ្លាំងណាស់-ដើម្បីពិភាក្សាជាមួយគាត់។ លោកហូលមែស សូមត្រលប់ទៅម៉ាកខ្លិតុនជាមួយខ្ញុំវិញនៅរថភ្លើងបន្ទាប់ទៅ។"

"ខ្ញុំសុំទោស វាមិនអាចទៅរួចទេ" ហូលមែសបាននិយាយ។ "ខ្ញុំកំពុងតែធ្វើការលើរឿងក្តីសំខាន់ៗពីរ-រឿងក្តីនៅហ្វេរេស និងរឿងក្តីអាបេហ្គេវិនី។ ក្នុងកំឡុងពេលហ្នឹង ខ្ញុំមិនអាចចាកចេញពីទីក្រុងឡុងបានទេ។"

"រឿងក្តីសំខាន់!" ភ្ញៀវរបស់យើងបានស្រែក។ "ប៉ុន្តែរឿងក្តីនេះក៏សំខាន់ណាស់ដែរ។ លោកមានដឹងពីការចាប់ជំរិតកូនប្រុសអភិជននៃត្រកូលហូលដឺនែសកាលពីបីថ្ងៃកន្លងទៅនេះទេ..."

"ស្អីគេ! មន្ត្រីរាជការរឺ?"

"មែនហើយ គាត់ហ្នឹងហើយ។ អញ្ចឹងលោកមិនបានដឹងទេ...វាមិនទៅចុះនៅក្នុងកាសែតទេ នោះគឺជាការពិត។ ប៉ុន្តែខ្ញុំគិតថា ស្ស៊ឺឡក់ ហូលមែសតែងតែដឹងដំណឹងមុនមនុស្សដទៃទៀត។"

ហូលមែសបានដើរទៅរកសៀវភៅគាត់មួយក្បាល ហើយចាប់ផ្តើមអានអំពីអភិជននៃត្រកូលហូលដឺនែស។

"ហូដឺនេស អភិជនទីប្រាំមួយ។ ប្រពន្ធឈ្មោះ៖ អេឌីតស៍ ជាបុត្រីនៃអភិជនហ្រ្គេ។ មានកូនម្នាក់ឈ្មោះ អភិជនអស់សឺ សាល់ទៃរ។ ផ្ទះនៅក្នុងទីក្រុងឡុង ឡានកាស៊ែ និងវ៉េលស៍។ មន្ត្រីរាជការសម្រាប់នេះ...សម្រាប់នោះ...សម្រាប់ផ្សេងៗទៀត...ល្អ ល្អ" ហូលមែសបាននិយាយ។ "គាត់គឺជាមនុស្សដ៏អស្ចារ្យម្នាក់នៅក្នុងប្រទេស។"

"ម្នាក់ក្នុងចំនោមអច្ឆរិយៈ ហើយម្នាក់ក្នុងចំនោមអ្នកមានស្តុកស្តម្ភបំផុត" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបាននិយាយ។ "លោកហូលមែស ខ្ញុំដឹងថាលោកមិនធ្វើការដើម្បីប្រាក់នោះទេ ប៉ុន្តែខ្ញុំត្រូវតែប្រាប់លោកនូវរឿងនេះ។ អភិជននេះនឹងប្រគល់ប្រាក់ប្រាំពាន់ផោនសម្រាប់ដំណឹងកូនប្រុសរបស់គាត់ ហើយប្រាក់ប្រាំពាន់ផោនទៀតសម្រាប់ឈ្មោះអ្នកចាប់ជំរិត។"

"នោះ" ហូលមែសបានស្រដី "គឺជាសម្បទានដ៏គួរឲ្យចាប់អារម្មណ៍បំផុត។" គាត់បានសម្លឹងមើលមកខ្ញុំ។ "វ៉ាត់សាន់ គ្នាគិតថាយើងត្រលប់ទៅខាងជើងប្រទេសអង់គ្លេសជាមួយវេជ្ជបណ្ឌិតហ៊ុកស៍ថាបលនាពេលរសៀលនេះ។"

បន្ទាប់មកហូលមែសបានសម្លឹងមកវេជ្ជបណ្ឌិតហ៊ុកស៍ថាបល។ "ឥលូវ លោកប្រាប់ខ្ញុំពីអ្វីៗគ្រប់យ៉ាងទៅមើល។ តើមានអ្វីកើតឡើង? តើវាកើតឡើងនៅពេលណា? តើវាកើតឡើងដោយរបៀបណា? ហើយហេតុអ្វីបានជាវេជ្ជបណ្ឌិតថនីក្រហ្វ ហ៊ុកស៍ថាបលមកសុំឲ្យខ្ញុំជួយនៅបីថ្ងៃក្រោយមក?

ភ្ញៀវរបស់យើងផឹកទឹកបន្តិច ហើយចាប់ផ្តើមនិយាយរឿងរបស់គាត់។

# វគ្គ ២

# ដំណើររឿងរបស់វេជ្ជបណ្ឌិតហ៊ុកស៍ថាបល

*"សាលារបស់ខ្ញុំ-សាលាបព្វជិតជិតម៉ាកខ្វិតុន-គឺជាសាលាដ៏ល្អបំផុតសម្រាប់ក្មេងប្រុសៗក្នុងប្រទេសអង់គ្លេស" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបានចាប់ផ្តើម។ "យើងមានកូននៃអភិជនសោមេស អភិជនលេវើ ហើយនិងកូនមនុស្សសំខាន់ៗជាច្រើនទៀត។ កាលពីបីសប្តាហ៍កន្លងទៅ លោកជេមស៍ វ៉ាលដឺរ ដែលត្រូវជាលេខារបស់អភិជននៃហូលដឺនេស បានមកជួបខ្ញុំ។ គេនិយាយថាលោកអភិជនចង់បញ្ជូនកូនរបស់គាត់ គឺអភិជនសាល់ទែរដែលមានអាយុដប់ឆ្នាំ មកកាន់សាលារបស់ខ្ញុំ។*

*"នៅថ្ងៃទីមួយខែឧសភាអភិជនសាលទែរបានមកដល់។ គេជាក្មេងប្រុសដ៏ស្រស់ស្អាតម្នាក់ ហើយមិនយូរប៉ុន្មាន គេក៏ចាប់ផ្តើមចូលចិត្តជីវិតនៅសាលា ហើយបង្កើតមិត្តភាពជាច្រើន។ ជីវិតរបស់គេនៅឯផ្ទះ លោកដឹងហើយ មិនសប្បាយចិត្តទាល់តែសោះ-ពួកយើងទាំងអស់សុទ្ធតែដឹងអំពីលោកអភិជន និងភរិយារបស់គាត់ហើយ។ ជាការពិតណាស់ អ្នកស្រីអភិជនឥលូវរស់នៅខាងត្បូងប្រទេសបារាំង។ ខ្ញុំគិតថានាងបានចាកចេញពីលោកអភិជនកាលពីបីខែមុន។ ប៉ុន្តែក្មេងប្រុសនេះស្រលាញ់ម្តាយរបស់គេ ហើយមិនសប្បាយចិត្តទាល់តែសោះនៅពេលដែលនាងចាកចេញទៅ។ ដោយសារតែហេតុនេះហើយ បានជាលោកអភិជនបញ្ជូនគេឲ្យមកសាលារបស់ខ្ញុំ។ ហើយក្រោយពីរស់នៅបានពីរសប្តាហ៍ជាមួយពួកយើង គេមានអារម្មណ៍រីករាយជាងមុន។*

"បន្ទាប់មក នៅយប់ថ្ងៃទី១៣ខែឧសភា គេបានបាត់ខ្លួន។ ផ្លូវទៅបន្ទប់គេងរបស់គេគឺត្រូវដើរឆ្លងកាត់បន្ទប់ធំជាហ្វឹងមួយផ្សេងទៀត។ ក្មេងប្រុសធំៗពីរនាក់ដេកនៅទីនោះ។ ម្នាក់ក្នុងចំណោមពួកគេមិនដែលដេកលក់ស្រួលទេ ហើយគេមិនឮ រឺក៏ឃើញអ្វីនៅយប់នោះទេ។ អញ្ចឹងអស់សឺរ័យក្មេងនេះមិនបានទៅតាមបន្ទប់នោះទេ។ បង្អួចរបស់គេបើកចំហ ហើយមានវល្លិនៅតាមជញ្ជាំងនៃផ្ទះនេះ។ វាជាការងាយស្រួលណាស់ក្នុងការចេញតាមបង្អួច ហើយចុះតាមវល្លិទៅដល់ដី។ អញ្ចឹងពួកយើងគិតថាគេចេញតាមផ្លូវនោះ។

"យើងគិតថាគេស្លៀកពាក់ឯកសណ្ឋានសាលាតាមធម្មតាទេ-គឺអាវធំខ្មៅដៃខ្លីមួយ និងខោជើងវែងពណ៌ខៀវចាស់។ ពួកយើងពិនិត្យមើលបន្ទប់គេយ៉ាងប្រុងប្រយ័ត្នជាទីបំផុត ប៉ុន្តែយើងគ្មានរកឃើញអ្វីចម្លែក គ្មានអ្វីដែលមិនធម្មតានោះទេ។

"នៅពេលដែលខ្ញុំបានស្វែងយល់តាមរយៈកាសែតនៅពេលព្រឹកម៉ោងប្រាំពីរព្រឹកថ្ងៃអង្គារ ខ្ញុំបានកោះហៅអ្នករាល់គ្នាឲ្យចូលទៅក្នុងសាលធំរបស់សាលា។ បន្ទាប់មក យើងបានដឹងនូវដំណឹងអាក្រក់បន្ថែមទៀត-ហេដិកហ្គើរ គ្រូបង្រៀនជនជាតិអាល្លឺម៉ង់ ក៏បាត់ខ្លួនដែរ។ បន្ទប់របស់គាត់នៅមិនឆ្ងាយពីបន្ទប់របស់អស់សឺប៉ុន្មានទេ។ ហេដិកហ្គើរវារចុះតាមវល្លិ-យើងដឹងរឿងនេះដោយសារយើងរកឃើញស្នាមជើងរបស់គាត់នៅលើដីខាងក្រោមបង្អួច។ យើងក៏ដឹងថាគាត់ស្លៀកតែអាវធំ ខោជើងវែង និងស្បែកជើងរបស់គាត់ប៉ុណ្ណោះ ពីព្រោះយើងរកឃើញអាវ និងស្រោមជើងរបស់គាត់នៅលើកម្រាលបន្ទប់របស់គាត់។ ហើយគាត់យកកង់របស់គាត់ទៅជាមួយ។

"ហេដិកហ្គើរមកសាលានេះមួយឆ្នាំកន្លងទៅហើយ។ គាត់គឺជាគ្រូបង្រៀនដ៏ល្អម្នាក់ ប៉ុន្តែក្មេងៗមិនសូវចូលចិត្តគាត់ប៉ុន្មានទេ ពីព្រោះគាត់មិនរាក់ទាក់ឡើយ។"

"អញ្ចឹង លោកហូលមែស ពួកយើងមានមនុស្សពីរនាក់បាត់ខ្លួន។ ឥលូវថ្ងៃព្រហស្បតិ៍ ហើយនៅតែគ្មានដំណឹងពីពួកគេទៀត។"

ហូលមែសបានយកសៀវភៅកំណត់ត្រាតូចមួយក្បាលចេញមក ហើយចាប់ផ្ដើមសរសេរ។

"ក្មេងប្រុសនោះមិនបានទៅផ្ទះទេ ជាការពិតណាស់" គាត់បាននិយាយ។

"ទេ ទេ។ ពួកយើងបានទៅសួរនៅគេហដ្ឋានហូលដឺនេសម្ដងហើយ" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបានស្រដី។ "លោកអភិជននេះខ្លាចកូនរបស់គាត់ខ្លាំងណាស់-ហើយឥលូវខ្ញុំគឺជាបុរសដែលមិនសប្បាយចិត្តបំផុតក្នុងប្រទេសអង់គ្លេស លោកគឺជាអ្នកស៊ើបអង្កេតដ៏ល្បីល្បាញម្នាក់-សូមជួយខ្ញុំផង!"

"លោកធ្វើឲ្យបញ្ហាកាន់តែពិបាកទៅហើយ" ហូលមែសបាននិយាយ។ "តើខ្ញុំអាចរកឃើញស្លាកស្នាមនៅជាប់នឹងវល្លិ៍ រឺក៏លើដីក្រោយពេលបីថ្ងៃយ៉ាងដូចម្ដេចទៅ? ហេតុអ្វីបានជាលោកមិនមករកខ្ញុំភ្លាមៗ?"

"គឺដោយសារតែលោកអភិជន" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបាននិយាយ។ "គាត់មិនចូលចិត្តឲ្យមានមនុស្សនិយាយអំពីជីវិតគ្រួសារដ៏អពមង្គលរបស់គាត់ឡើយ។"

"ហើយតើពួកប៉ូលីសកំពុងតែធ្វើអ្វី?"

"ពួកគេបានឮដំណឹងអំពីក្មេងប្រុស និងបុរសវ័យក្មេងម្នាក់នៅស្ថានីយ៍រថភ្លើងនាព្រឹកថ្ងៃអង្គារ។ ពួកគេបានស្វែងរកក្មេងប្រុសនិងបុរសម្នាក់នោះ ហើយចុងក្រោយប៉ូលីសបានរកឃើញពួកគេនៅលីវើភូល-ប៉ុន្តែវាគ្រាន់តែជាបុរសម្នាក់ និងកូនប្រុសរបស់គាត់ទៅលេងមិត្តភក្តិម្នាក់តែប៉ុណ្ណោះ។ ពួកយើងចំនាយអស់ពេលបីថ្ងៃដោយសារតែរឿងហ្នឹង។ ហើយយប់មុនខ្ញុំដេកមិនលក់ទេ អញ្ចឹងខ្ញុំក៏ជិះរថភ្លើងចុះមកទីក្រុងឡុងនៅព្រឹកនេះ។"

"ល្អ វេជ្ជបណ្ឌិតហ៊ុកស៍ថាបល សំនួរមួយចំនួនទៀត" ហូលមែសបានស្រដី។ "តើក្មេងប្រុសនោះមានរៀនមេរៀនភាសាអាល្លឺម៉ង់ដែររឺទេ?"

"ទេ។"

"អញ្ចឹងគេមិនស្គាល់គ្រូជនជាតិអាល្លឺម៉ង់ច្បាស់ទេ។"

"គេប្រហែលជាមិនដែលនិយាយទៅរកគាត់ទេ។" វេជ្ជបណ្ឌិតបាននិយាយ។

"អ៊ឹម" ហូលមែសបានស្រដី។ "តើក្មេងប្រុសនេះមានកង់ដែររឺទេ?"

"ទេ។"

"តើមានបាត់កង់ដែររឺទេ?"

"ទេ។"

"អញ្ចឹង។ តើគ្រូជនជាតិអាល្លឺម៉ង់យកកង់របស់គាត់ចេញទៅនៅពេលយប់ ដោយមានក្មេងប្រុសនេះនៅខាងក្រោយគាត់មែនទេ? ខ្ញុំមិនគិតថាអញ្ចឹងនោះទេ។ ប៉ុន្តែតើមានអ្វីកើតឡើងចំពោះកង់នោះ? ឥលូវ ចុះចំនែកភ្ញៀវវិញ? តើក្មេងប្រុសនោះមានភ្ញៀវមកលេងនៅថ្ងៃមុនៗដែររឺទេ?"

"ទេ។"

"តើគេមានទទួលបានសំបុត្រទេ?"

"មែនហើយ សំបុត្រមួយច្បាប់។ ពីឪពុករបស់គេ។"

"តើលោកមានបើកសំបុត្ររបស់ក្មេងប្រុសនោះទេ វេជ្ជបណ្ឌិតហ៊ុកស៍ថាបល?"

"ទេ។"

"អញ្ចឹងតើលោកម៉េចនឹងដឹងថាសំបុត្រនោះផ្ញើពីឪពុករបស់គេ?"

"ខ្ញុំស្គាល់អក្សរសរសេរដៃរបស់លោកអភិជន។ ហើយគាត់និយាយថាគាត់បានសរសេរសំបុត្រទៅកូនប្រុសរបស់គាត់។"

"តើក្មេងប្រុសនោះទទួលបានសំបុត្រពីប្រទេសបារាំងដែររឺទេ?"

"ទេ ខ្ញុំមិនដែលឃើញមួយច្បាប់ណាឡើយ។"

"តើលោកយល់ខ្ញុំនិយាយទេ វេជ្ជបណ្ឌិតហ៊ុកស៍ថាបល?" ហូលមែសបានស្រដី។ "តើមាននរណាម្នាក់យកក្មេងប្រុសនោះទៅ រឺក៏ក្មេងប្រុសនោះទៅតែម្នាក់ឯង?-ដោយសារប្រហែលជាគេទទួលបានសំបុត្រមួយច្បាប់ពីបារាំង។"

"ខ្ញុំមិនដឹងទេ" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបាននិយាយ។ "ខ្ញុំគិតថាគេទទួលសំបុត្រតែពីឪពុកគេប៉ុណ្ណោះ។"

"តើឪពុក និងកូនពាក់ទាក់ជាមួយគ្នាដែររឺទេ?"

"លោកអភិជនមិនទេ...អឺ...មិនមែនជាមនុស្សពាក់ទាក់ប៉ុន្មានទេ លោកហូលមែស។ គាត់មិនមែនជាឪពុកអាក្រក់នោះទេ ប៉ុន្តែគាត់គឺជាមន្ត្រីរាជការ ហើយមានការងារជាច្រើនដែលត្រូវធ្វើ។"

"អញ្ចឹងក្មេងប្រុសនោះមានអារម្មណ៍ពាក់ទាក់ជាងចំពោះម្តាយរបស់គេរឺ?"

"មែនហើយ។"

"តើគាត់មាននិយាយដូច្នោះទេ?"

"ទេ។"

"តើលោកអភិជនមានប្រាប់លោកដែររឺទេ អញ្ចឹង?"

"អូ ទេ! លោកអភិជនមិនដែលនិយាយរឿងដូច្នោះឡើយ។"

អញ្ចឹងតើលោកដឹងដោយរបៀបណា?"

"លោកជេមស៍ វ៉ាលដឺរ ដែលត្រូវជាលេខារបស់លោកអភិជន បានប្រាប់ខ្ញុំ។"

"ខ្ញុំដឹងហើយ" ហូលមែសបាននិយាយ។ "សំបុត្រចុងក្រោយរបស់លោកអភិជន-តើឥលូវវានៅឯណា?"

"ក្មេងប្រុសនោះបានយកទៅជាមួយហើយ" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបានស្រដី។ "វាមិននៅក្នុងបន្ទប់របស់គេទេ។ លោកហូលមែស-សល់តែកន្លះម៉ោងទៀត រថភ្លើងរបស់យើងចេញដំណើរហើយ។"

"ត្រូវហើយ" ហូលមែសបាននិយាយ។ គាត់បានសម្លឹងមើលមកខ្ញុំ។ "វ៉ាត់សាន់ រៀបចំអីវ៉ាន់ទៅហើយចុះទៅទិសខាងត្បូងជាមួយនឹងវេជ្ជបណ្ឌិតហ៊ុកស៍ថាបល។ ប្រហែលជាយើងអាចរកឃើញចម្លើយមួយចំនួនទៅកាន់អាថ៌កំបាំងនេះ។"

# វគ្គ ៣
# ដំណើរទៅទិសខាងត្បូង

*វាព្រលប់ទៅហើយនៅពេលដែលយើងបានទៅដល់សាលាដ៏ល្បីល្បាញរបស់វេជ្ជបណ្ឌិតហ៊ុកស៍ថាបល នៅជ្រលងភ្នំខាងត្បូង។ យើងបានចូលទៅក្នុងអគារយ៉ាងរហ័សដើម្បីកុំឲ្យរងា ហើយរំពេចនោះនរណាម្នាក់បានរត់ឡើងមកដោយមានដំណឹងសម្រាប់វេជ្ជបណ្ឌិតហ៊ុកស៍ថាបល។*

*គាត់មើលទៅដូចជាភ្ញាក់ផ្អើលណាស់។ "លោកអភិជននៅទីនេះឯង" គាត់បានប្រាប់ពួកយើង។ "លោកអភិជន និងលោកវ៉ាលដឺរ ដែលត្រូវជាលេខារបស់គាត់ គឺនៅក្នុងការិយាល័យរបស់ខ្ញុំ។ មកជួបពួកគេទៅ។"*

*មន្ត្រីរាជការម្នាក់នោះគឺជាបុរសខ្ពស់ម្នាក់ដែលមានមុខស្គមវែង។ គាត់មានសក់ពណ៌ក្រហម ហើយមានពុកចង្កាពណ៌ក្រហមដ៏សំបើមមួយ។ គាត់បានសម្លឹងមើលពួកយើង ប៉ុន្តែមិនញញឹមបន្តិចសោះ។ លោកវ៉ាលដឺរឈរនៅក្បែរគាត់ គេជាបុរសដ៏វ័យក្មេងម្នាក់។ គេមានរាងតូច ដោយមានភ្នែកពណ៌ខៀវ ហើយមានទឹកមុខប្រយ័ត្នប្រយែង។ គេនិយាយមុនដំបូងគេ។*

*"លោកអភិជនមានការភ្ញាក់ផ្អើលណាស់ វេជ្ជបណ្ឌិតហ៊ុកស៍ថាបល ដែលបានជួបលោកស្សឺឡក់ហូលមែសនៅទីនេះ។ គាត់មិនចង់ឲ្យនរណាម្នាក់ដឹងអំពីរឿងនេះឡើយ។ លោកដឹងរឿងនេះហើយ អញ្ចឹងហេតុអ្វីបានជាលោកមិនប្រាប់លោកអភិជនជាមុនមុននឹងលោកទៅទីក្រុងឡុង?"*

"ប៉ុន្តែយើងត្រូវការជំនួយ" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបាននិយាយ។ "ហើយខ្ញុំ..."

"ល្អ" លោកអភិជនបានស្រដី។ "លោកហូលមែសនៅទីនេះហើយឥលូវ ហើយប្រហែលជាគាត់អាចជួយពួកយើងបាន។" គាត់បានសម្លឹងមើលមកហូលមែស។ "ខ្ញុំចង់ឲ្យលោកមកស្នាក់នៅឯគេហដ្ឋានហូលដឺនែស លោកហូលមែស។"

"អរគុណលោកហើយ" ហូលមែសបាននិយាយ។ "ប៉ុន្តែខ្ញុំចង់នៅជិតនឹងអាថ៌កំបាំងជាង គឺចង់ស្នាក់នៅទីនេះក្នុងសាលា។ តើខ្ញុំអាចសួរលោកពីរបីសំនួរបានទេ?"

"ជាការពិតណាស់" លោកអភិជនបាននិយាយ។

"សំនួររបស់ខ្ញុំគឺអំពីអ្នកស្រីអភិជន ហើយអំពីរឿងប្រាក់" ហូលមែសបានស្រដី។

"អ្នកស្រីអភិជនមិនដឹងរឿងនេះបន្តិចទេ" លោកអភិជនបាននិយាយ "ហើយគ្មាននរណាស្នើខ្ញុំអំពីរឿងប្រាក់នោះដែរ។"

"ខ្ញុំដឹងហើយ" ហូលមែសបានស្រដី។ "លោកបានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅឲ្យកូនរបស់លោក។ តើលោកដាក់វានៅប៉ុស្តិ៍ប្រៃសណីយ៍ពេលណា?"

"ដាក់នៅប៉ុស្តិ៍ប្រៃសណីយ៍?" លោកវ៉ាលដឺរបាននិយាយយ៉ាងខឹងសំបារ។ "លោកអភិជនមិនបានដាក់វានៅប៉ុស្តិ៍ប្រៃសណីយ៍ទេ។ ខ្ញុំបានដាក់សំបុត្រនោះនៅក្នុងថង់សំបុត្រ ជាមួយនឹងសំបុត្រដទៃទៀតនៅថ្ងៃ

នោះ។"

ពីរបីនាទីក្រោយមក លោកអភិជន និងលោកវ៉ាលដឺរបានចាកចេញទៅ។ បន្ទាប់មក ហូលមែសបានចាប់ផ្តើមធ្វើការលើរឿងក្តីមួយរំពេច។ ពួកយើងពិនិត្យមើលយ៉ាងប្រុងប្រយ័ត្ននៅក្នុងបន្ទប់ក្មេងប្រុសនោះគ្រប់ជ្រុងជ្រោយ។ ពួកយើងបានពិនិត្យមើលវល្លិ៍នៅលើជញ្ជាំង ហើយនិងបន្ទប់គ្រូបង្រៀនជនជាតិអាល្លឺម៉ង់ ហើយពួកយើងរកឃើញដានជើងនៅក្រោមបង្អួចរបស់គ្រូបង្រៀនជនជាតិអាល្លឺម៉ង់នោះ។ ប៉ុន្តែពួកយើងគ្មានរកឃើញអ្វីថ្មីនោះទេ។ បន្ទាប់មក ហូលមែសបានចាកចេញពីផ្ទះ ហើយត្រលប់មកវិញលុះត្រាតែដល់ម៉ោងដប់មួយ។

គាត់យកផែនទីដ៏ធំមួយទៅតាម។ គាត់បានយកវាទៅក្នុងបន្ទប់របស់ខ្ញុំ ហើយដាក់វានៅលើគ្រែ។

"រឿងក្តីនេះចាប់ផ្តើមកាន់តែគួរឲ្យចាប់អារម្មណ៍ហើយ វ៉ាត់សាន់" គាត់បាននិយាយ។ "មើលផែនទីនេះទៅ។ នេះគឺជាសាលា ឯងឃើញទេ ហើយនេះគឺជាផ្លូវ។ អញ្ចឹង តើក្មេងប្រុស និងគ្រូបង្រៀននោះទៅតាមផ្លូវដែលពួកគេបានចាកចេញដែររឺទេ? ទេ វ៉ាត់សាន់ គេមិនបានទៅតាមផ្លូវហ្នឹងទេ!"

"តើឯងម៉េចនឹងដឹង ហូលមែស?" ខ្ញុំបានសួរ។

"ពីព្រោះមានប៉ូលីសម្នាក់នៅទីនេះ-មើលទៅ។ គេនៅទីនោះចាប់ពីពាក់កណ្តាលអធ្រាត្ររហូតដល់ម៉ោងប្រាំមួយព្រឹក ហើយគេគ្មានឃើញនរណាម្នាក់នៅលើផ្លូវទេ។ គ្នាបាននិយាយជាមួយគេកាលពីល្ងាចនេះ។ ហើយទីនេះនៅចុងម្ខាងទៀត ឯងឃើញទេ គឺជាសណ្ឋាគារសេះស។ ស្ត្រីម្នាក់នៅទីនោះមានជម្ងឺ ហើយគ្រួសារនោះឃ្លាំមើលផ្លូវជារៀងរាល់យប់ រង់ចាំវេជ្ជបណ្ឌិតមកដល់។ វេជ្ជបណ្ឌិតមិនបានមកដល់រហូតដល់ពេលព្រឹកព្រលឹម ហើយគ្រួសារនោះគ្មានឃើញនរណាម្នាក់នៅលើផ្លូវឡើយ។ អញ្ចឹងក្មេងប្រុសនោះ និងគ្រូបង្រៀនមិនបានទៅតាមផ្លូវលំទេ។"

"ប៉ុន្តែ ហូលមែស ចុះចំនែកកង់វិញ?" ខ្ញុំបានសួរ។

"មែនហើយ វ៉ាត់សាន់ យើងត្រូវតែចងចាំរឿងកង់ ជាការពិតណាស់។ ប៉ុន្តែដំបូង តោះសម្លឹងមើលទិសខាងត្បូង និងខាងជើងសិន។ ទៅខាងត្បូងមានទន្លេដ៏ធំមួយ-អញ្ចឹងគ្មានកង់នៅទីនោះទេ។ ហើយទៅទិសខាងជើងមានដើមឈើជាច្រើន ដែលហៅថា រេកស៊ រ ហើយបន្ទាប់មកគឺជាវាលទំនាបដ៏ធំមួយ គឺវាលទំនាបលោវើ ហ្គិល។ ហើយនេះគឺជាគេហដ្ឋានហូលដឺនែស មានចម្ងាយដប់ប្រាំមួយគីឡូម៉ែតពីសាលាបើជិះតាមផ្លូវ ប៉ុន្តែមានចម្ងាយត្រឹមតែប្រាំបួនគីឡូម៉ែតប៉ុណ្ណោះបើទៅតាមវាលទំនាប។ គ្មានផ្ទះទៀតទេរហូតដល់សណ្ឋាគារហ្វ្រីនមែន នៅតាមផ្លូវឆេសតឺហ្វៀល។"

"ប៉ុន្តែកង់នោះ?" ខ្ញុំបាននិយាយម្តងទៀត។

"មែនហើយ មែនហើយ វ៉ាត់សាន់!" ហូលមែសបានស្រដី។ "វាអាចទៅរួចក្នុងការជិះកង់ឆ្លងកាត់វាលទំនាប-ពិបាក ប៉ុន្តែអាចទៅរួច។"

ស្រាប់តែបន្ទាប់មក វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបានចូលមកក្នុងបន្ទប់នោះយ៉ាងប្រញាប់ប្រញាល់។ "ដំណឹង លោកហូលមែស!" គាត់បានស្រដីយ៉ាងរំភើប។ "ខ្ញុំនាំដំនឹងមកហើយ!" នៅក្នុងដៃរបស់គាត់មានមួកសាលាពណ៌ខៀវមួយ។ "មើលនែក-នេះគឺជាមួករបស់ក្មេងប្រុសនោះ។ ម្នាក់ក្នុងចំណោមអ្នកថែសួនច្បាររបស់ខ្ញុំបានរកឃើញនៅល្ងាចនេះ។"

"នៅកន្លែងណា?" ហូលមែសបានសួរ។



"នៅទិសខាងជើងរេកស៊ិរ" វេជ្ជបណ្ឌិតហ៊ុកស៍ថាបលបានស្រដី។

"អាហា!" ហូលមែសបាននិយាយ។ "តើគ្នាបានប្រាប់ឯងអ្វីអំបាញ់មិញ វ៉ាត់សាន់? ថ្ងៃស្អែកយើងត្រូវតែដើរទៅទិសខាងជើង កាត់តាមវាលទំនាប។"



# វគ្គ ៤

# សាកសពនៅលើវាលទំនាប

*យ៉ាងព្រលឹមនៅពេលព្រឹក ខ្ញុំបានបើកភ្នែករបស់ខ្ញុំ ហើយឃើញហូលមែសនៅក្បែរគ្រែរបស់ខ្ញុំ។ គាត់ស្លៀកពាក់រួចរាល់អស់ហើយ។*

*“មក វ៉ាត់សាន់” គាត់បានស្រែក។ “មានកាហ្វេក្តៅទុកឲ្យឯងរួចស្រេចហើយ។ យើងនឹងចាកចេញក្នុងពេលដប់នាទីទៀត។*

*នៅម៉ោងប្រាំមួយយើងកំពុងតែនៅក្នុងរទេះសេះ ហើយកន្លះម៉ោងក្រោយមក យើងនៅលើវាលទំនាបលោវ៉ើហ្គីល។ មានទន្លេតូចមួយហូរកាត់ចំកណ្តាលវាលទំនាប ហើយដីនៅជុំវិញពិតជាសើមខ្លាំងណាស់។*

*“យើងអាចមើលឃើញដានយ៉ាងស្រួលនៅលើដីសើមនេះ” ហូលមែសបានស្រដី។ “មើលឲ្យប្រយ័ត្នប្រយែងណា៎ វ៉ាត់សាន់!”*

*ពួកយើងធ្វើដំណើរយ៉ាងយឺតៗលើវាលទំនាប សម្លឹងមើលទៅគ្រប់ជ្រុងជ្រោយនៃភក់ទាំងអស់។ យើងរកឃើញដានជើងសត្វចៀមជាច្រើន ហើយដានជើងគោ-ប៉ុន្តែគ្មានដានកង់នោះទេ។ ហើយបន្ទាប់មកនៅចុងក្រោយ យើងបានរកឃើញអ្វីម្យ៉ាង។ នៅមិនឆ្ងាយពីទន្លេតូចនោះ កាត់តាមភក់ពណ៌ខ្មៅដ៏ស្រស់ស្អាតមួយចំនួន មានដានជើងកង់មួយ។*

"ជយោ" ខ្ញុំបានស្រែក។ "យើងរកឃើញហើយ!"

ប៉ុន្តែហូលមែសមើលទៅដូចជាមិនសប្បាយចិត្តទេ។ "វាជាស្នាមកង់ មែនហើយ ប៉ុន្តែមិនមែនជាកង់ទេ។ ពល់កង់ទាំងអស់តែងតែមានកង់ផ្សេងៗគ្នា-ខ្ញុំស្គាល់ប្រភេទកង់សែសិបពីរមុខ។ កង់នេះគឺប្រភេទឌុនលុប ប៉ុន្តែកង់ហេដិកហ្គើរមានកង់ប្រភេទផាមម័រ។ គ្រូបង្រៀនជនជាតិអង់គ្លេសបានប្រាប់ខ្ញុំពីរឿងនោះ។ អញ្ចឹងនេះមិនមែនជាហេដិកហ្គើរទេ។"

"អញ្ចឹង តើវាជាកង់របស់ក្មេងប្រុសនោះរឺ?"

"ប្រហែលជាមិនមែនទេ។ ក្មេងប្រុសនោះមិនយកកង់ទៅនោះទេ" ហូលមែសបាននិយាយ។ គាត់សម្លឹងមើលដាននៅក្នុងភក់ម្តងទៀត។ "ដាននេះទៅឆ្ងាយពីសាលា។"

"រឺក៏ប្រហែលជាទៅសាលា?" ខ្ញុំបានស្រដី។

"ទេ ទេ សម្លាញ់វ៉ាត់សាន់។ មើលទៅដានកង់ទាំងពីរទៅមើល។ តើពួកវាដូចគ្នាដែររឺទេ?"

"អឺ...ទេ" ខ្ញុំបាននិយាយ។ "កង់ម្ខាងមានដានជ្រៅជាង។"

"អញ្ចឹងវាជាកង់ក្រោយ" ហូលមែសបានស្រដី "ជាការពិតណាស់ ដោយសារតែមានអ្នកជិះអង្គុយនៅខាងក្រោយ។ ដានជ្រៅជាងគេគឺនៅខាងលើ អញ្ចឹងកង់នេះច្បាស់ជាទៅតាមផ្លូវនោះហើយ កាត់តាមវាលទំនាបចេញពីសាលា។ ប៉ុន្តែតើនរណាគេជាអ្នកជិះនោះ? តើគេមកពីណា?"

ពួកយើងបានតាមដានកង់ឌុនលុបត្រលប់មកវិញ ជិតទៅដល់វេកសិរ។ បន្ទាប់មកយើងក៏បាត់ដាននោះ ដោយដានជើងគោមួយចំនួន។ ហូលមែសបានអង្គុយចុះ ហើយគិតអស់មួយស្របក់។

"ទេ" គាត់បាននិយាយ ដោយក្រោកឡើង។ "យើងត្រូវតែទុកសំនួរនេះមួយលែកសិន។ ត្រលប់ទៅទីភក់ជិតទន្លេវិញ វ៉ាត់សាន់!"

ពីរម៉ោងក្រោយមក ហូលមែសបានផ្តល់នូវសំរែកដ៏រីករាយមួយ។ ខ្ញុំបានរត់ទៅរកគាត់យ៉ាងរហ័ស ហើយសម្លឹងមើលចុះក្រោយទៅកាន់ដានតូចដ៏វែងមួយនៅក្នុងភក់។ វាគឺជាកង់ផាមម័រ។

"នេះគឺជាកង់ហេដិកហ្គើរហើយ!" ហូលមែសបានស្រែក។ "តោះទៅតាម វ៉ាត់សាន់។"

អស់មួយគីឡូម៉ែតរឺច្រើនជាងហ្នឹងដែលយើងតាមដានកង់ផាមម័រកាត់តាមវាលទំនាប បាត់ដានរកឃើញម្តងទៀត បាត់ទៀត ហើយរកឃើញទៀត។ ភ្លាមនោះ ដានក៏បានឈប់។

"តើមានអ្វីកើតឡើងនៅទីនេះ?" ខ្ញុំបានស្រដី។ "តើគាត់ដួលរឺ?"

ហូលមែសបានសម្លឹងមើលយ៉ាងប្រុងប្រយ័ត្ននៅលើដី។ បន្ទាប់មក គាត់បានដើរទៅគុម្ពោតព្រៃតូចៗដោយមានផ្កាពណ៌លឿងនៅលើពួកវា។ "មើលនុះ" គាត់បាននិយាយយ៉ាងស្ងាត់ៗ។

នៅលើផ្កាពណ៌លឿង មានអ្វីម្យ៉ាងពណ៌ក្រហម-គឺជាឈាមពណ៌ក្រហមក្រម៉ៅ។

"អាក្រក់មែន!" ហូលមែសបាននិយាយ។ "អាក្រក់ណាស់! តើខ្ញុំសន្និដ្ឋានថាមានអ្វីកើតឡើងនៅទីនេះ? មានអ្វីម្យ៉ាង រឺក៏នរណាម្នាក់បានវាយគេ។ គេបានដួល គេបានក្រោកឡើង ហើយឡើងជិះកង់ម្តងទៀត ហើយបរទៅឆ្ងាយ។ ប៉ុន្តែគ្មានដានទៀតទេ។ មានដានជើងគោមួយចំនួននៅទីនេះ ប៉ុន្តែគ្មានដានជើងមនុស្សនោះទេ។ យើងត្រូវតែទៅតាមឈាម វ៉ាត់សាន់។"

មិនយូរប៉ុន្មាន យើងក៏រកឃើញកង់នោះ ហើយបន្ទាប់មកនៅខាងក្រោយគុម្ពោតយើងបានរកឃើញស្បែកជើង ហើយរកឃើញសាកសពមួយ។ មានឈាមនៅលើក្បាល និងមុខរបស់បុរសម្នាក់នោះ ហើយគេពិតជាស្លាប់មែនទែន។ គេពាក់ស្បែកជើង ប៉ុន្តែគ្មានស្រោមជើងទេ ហើយយើងឃើញមានអាវពាក់ដេកយប់មួយនៅខាងក្រោមអាវធំរបស់គេ។ សាកសពនេះគឺជាគ្រូបង្រៀនជនជាតិអាល្លឺម៉ង់។

"បុរសកំសត់" ហូលមែសបាននិយាយយ៉ាងស្ងៀមស្ងាត់។ "តើយើងនឹងធ្វើអ្វីទៀត វ៉ាត់សាន់? យើងមិនអាចបាត់បង់ពេលវេលាទៀតនោះទេ ប៉ុន្តែយើងត្រូវតែប្រាប់នរណាម្នាក់អំពីបុរសកំសត់ម្នាក់នេះ។"

"តើគ្នាគួរតែត្រលប់ទៅសាលាវិញទេ?" ខ្ញុំបាននិយាយ។

"ទេ គ្នាត្រូវការឯងឲ្យនៅជាមួយគ្នា។" ហូលមែសបានក្រោកឈរឡើង ហើយសម្លឹងមើលជុំវិញ។ "មើលណ៎!" គាត់បានស្រដី។ "មានកម្មករម្នាក់នៅទីនោះ។ គេអាចរត់ត្រលប់ទៅសាលាជំនួសពួកយើងបាន។"

ខ្ញុំបានទៅនាំកម្មករម្នាក់នោះមក ហើយហូលមែសបានសរសេរសារមួយសម្រាប់វេជ្ជបណ្ឌិតហ៊ុកស៍ថាបល។ កម្មករកំសត់នោះបានសម្លឹងមើលទៅសាកសពនោះ ហើយចាប់ផ្តើមរត់យ៉ាងរហ័សចុះជ្រលងភ្នំទៅរេកស៊ីរ។

"ឥលូវ" ហូលមែសបាននិយាយ។ "មុនពេលដែលយើងបន្តទៅមុខទៀត គិតឲ្យបានល្អិតល្អន់មួយភ្លែតសិន។ តើមកទល់ពេលនេះយើងបានដឹងអ្វីខ្លះហើយ? មុនដំបូង ក្មេងប្រុសនោះបានចាកចេញតែម្នាក់ឯង។ គេស្លៀកពាក់ឲ្យបានរួចរាល់ គេមិនចាកចេញទាំងភ្លាមៗនោះទេ គេចង់ទៅ-ប្រហែលជាចង់ទៅជាមួយនរណាម្នាក់ ប្រហែលជាមិនមែនអញ្ចឹងទេ។ ប៉ុន្តែគ្រូបង្រៀនជនជាតិអាល្លឺម៉ង់បានចាកចេញដោយមិនពាក់ស្រោមជើង និងអាវរបស់គាត់ទេ អញ្ចឹងគាត់ប្រាកដជាចាកចេញភ្លាមៗហើយ។"

"ត្រូវហើយ" ខ្ញុំបាននិយាយ។

"ហើយហេតុអ្វីបានជាហេជិកហ្គើរចេញទៅ? ពីព្រោះ តាមបង្អួចបន្ទប់គេងរបស់គាត់ គាត់បានឃើញក្មេងប្រុសនោះ។ ដោយសារតែគាត់ចង់ទៅតាមគេ ហើយនាំគេត្រលប់មកវិញ។ មកដល់ពេលនេះអ្វីៗគ្រប់យ៉ាងមិនអីទេ។ ប៉ុន្តែហេតុអ្វីបានជាគេមិនរត់តាមក្មេងប្រុសនោះ? បុរសម្នាក់អាចរត់លឿនជាងក្មេងប្រុសនោះយ៉ាងងាយស្រួលជាទីបំផុត-ប៉ុន្តែហេជិកហ្គើរមិនធ្វើបែបនេះទេ។ គេជិះកង់របស់គេដេញតាម។ គេដឹងថាគេត្រូវការកង់របស់គេ។ ហេតុអ្វី?"

"អា" ខ្ញុំបានស្រដី។ "ដោយសារក្មេងប្រុសនោះមានកង់។"

"កុំប្រញាប់សន្និដ្ឋានពេក វ៉ាត់សាន់។ គិតឲ្យច្បាស់ទៅមើល។ ហេជិចហ្គឺរស្លាប់នៅចម្ងាយប្រាំបីគីឡូម៉ែតពីសាលា។ អញ្ចឹងក្មេងប្រុសនោះធ្វើដំណើរលឿនខ្លាំងណាស់ ដោយសារតែវាត្រូវចំនាយអស់ប្រាំបីគីឡូម៉ែតមុនពេលដែលបុរសម្នាក់ជិះកង់អាចទៅជិតគេបាន។ ហើយហេជិកហ្គើរស្លាប់ដោយសារមាននរណាម្នាក់វាយគេយ៉ាងខ្លាំងត្រូវក្បាល។ ក្មេងប្រុសម្នាក់មិនអាចធ្វើរឿងនោះបានទេ អញ្ចឹងប្រាកដជាមាននរណាម្នាក់នៅជាមួយក្មេងប្រុសនោះ-អាចនិយាយបានថាបុរសម្នាក់។ ប៉ុន្តែពួកយើងបានសម្លឹងមើលយ៉ាងប្រុងប្រយ័ត្នលើកក់ដែលនៅជុំវិញសាកសពរបស់ហេជិចហ្គឺរគ្រប់ជ្រុងជ្រោយអស់ហើយ

វ៉ាត់សាន់ ហើយតើយើងមានរកឃើញអ្វីទេ? ដានជើងគោមួយចំនួន ប៉ុន្តែគ្មានអ្វីទៀតទេ។ គ្មានដានជើងមនុស្សឡើយ គ្មានដានកង់ទេ។"

"ហូលមែស" ខ្ញុំបានស្រែក។ "នេះវាមិនអាចទៅរួចទេ។"

"ល្អណាស់ វ៉ាត់សាន់" គាត់បាននិយាយ។ "វាមិនអាចទៅរួចទេ អញ្ចឹងមានអ្វីផ្គាំផ្គងចំពោះការគិតរបស់គ្នាហើយ។ តើវាអាចជាអ្វីទៅហ្ន៎?"

"ប្រហែលជា" ខ្ញុំបានស្រដី "ហេជិកហ្គើរបែកក្បាលដោយសារតែគាត់ដួលរឺ?"

"ក្នុងភក់រឺ វ៉ាត់សាន់?"

"អូ ខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងអ្វីទេ។"

"មកឲ្យលឿនឡើង វ៉ាត់សាន់" ហូលមែសបាននិយាយ។ "រាល់អាថ៌កំបាំងទាំងឡាយតែងតែមានចម្លើយរបស់វា។ ប៉ុន្តែពេលឥលូវ កង់ផាមម័រមិនអាចប្រាប់យើងនូវអ្វីទៀតបានឡើយ អញ្ចឹងពួកយើងត្រូវតែត្រលប់ទៅតាមដានកង់ឌុនលុបវិញ។"

ពួកយើងបានរកឃើញដានកង់ឌុនលុបម្តងទៀត ហើយតាមវាទៅទិសខាងជើង។ នៅទីនេះមានភក់តិចណាស់ ហើយយើងក៏បាត់ដាននោះ។ ធ្ងន់កាត់វាលទំនាប ឥលូវយើងអាចមើលឃើញគេហដ្ឋានហូលដឺនែសហើយ នៅប៉ុន្មានគីឡូម៉ែតពីពួកយើង ហើយនៅ ពីមុខពួកយើង ពួកយើងអាចមើលឃើញផ្លូវឆេសតឺហ្វៀល។ ពួកយើងបានដើរចុះទៅផ្លូវនោះ ហើយដើរសំដៅទីសណ្ឋាគារហ្វ្រីនមែន។



# វគ្គ ៥

# ការធ្វើដំណើរទៅសណ្ឋាគារហ្គ្រីនមែន

*នៅពេលដែលយើងជិតទៅដល់សណ្ឋាគារ ភ្លាមនោះហូលមែសក៏ស្រែក។ "អា! ជើងរបស់ខ្ញុំ! ខ្ញុំមិនអាចឈរបានទៀតទេ។ ជួយខ្ញុំផង វ៉ាត់សាន់។"*

*ខ្ញុំបានគ្រាប់គាត់ ហើយពួកយើងបានដើរយ៉ាងយឺតៗទៅកាន់ទ្វារសណ្ឋាគារ។ បុរសម្នាក់ឈរនៅទីនោះ កំពុងតែជក់បារី ហើយសម្លឹងមើលមកពួកយើង។*

*"តើលោកសុខសប្បាយជាទេ លោករូបេន ហាយែស?" ហូលមែសបាននិយាយ។*

*"តើលោកជានរណា ហើយហេតុអ្វីបានជាលោកស្គាល់ឈ្មោះរបស់ខ្ញុំ?" បុរសនោះបានស្រដី។ គាត់មើលទៅដូចជាមិនរាក់ទាក់ឡើយ។*

*"ពីព្រោះវានៅលើទ្វារសណ្ឋាគារ ពីលើក្បាលរបស់លោក" ហូលមែសបាននិយាយ។ "ប៉ុន្តែតើលោកអាចជួយខ្ញុំបានដែរឬទេ លោកហាយែស?"*

*"ទេ ខ្ញុំជួយមិនបានទេ។"*

*"ប៉ុន្តែខ្ញុំត្រូវការជំនួយ។ ខ្ញុំឈរលេងនឹងហើយ។"*

*"ល្អ កុំឈរលើដីអីអញ្ចឹង។"*

ហូលមែសបានញញឹម។ "ស្តាប់ណា៎" គាត់បាននិយាយ។ "វាសំខាន់ខ្លាំងណាស់ ហើយខ្ញុំអាចបង់ថ្លៃឲ្យលោកមួយផោនសម្រាប់ការប្រើប្រាស់កង់មួយគ្រឿង។"

"តើលោកចង់ទៅណា?" លោកហាយែសបានស្រដី។

"ទៅគេហដ្ឋានហូលដឺនេស។"

"អូ តើលោកជាមិត្តភក្តិរបស់លោកអភិជនរឺ?" លោកហាយែសបានសើច ដោយសម្លឹងមើលស្បែកជើង និងខោប្រលាក់ភក់របស់ពួកយើង។"

ហូលមែសក៏សើចដែរ។ "ពួកយើងនឹងយកដំនឹងទៅប្រាប់គាត់ពីការបាត់ខ្លួនរបស់កូនគាត់។" គាត់បានស្រដី។ "ក្មេងប្រុសនោះនៅក្នុងលីវើរ៉ិកូល។"

មុខរបស់លោកហាយែសក៏ក្លាយជាស្លេកស្លាំង បន្ទាប់មកឡើងក្រហម។ "អូ" គាត់បាននិយាយយ៉ាងប្រុងប្រយ័ត្ន។ "នោះគឺជា...អឺ នោះគឺជាដំនឹងល្អ។ ខ្ញុំធ្លាប់ធ្វើការឲ្យលោកអភិជនម្តងដែរ ប៉ុន្តែគាត់មិនល្អចំពោះខ្ញុំឡើយ។ ខ្ញុំមិនចូលចិត្តគាត់ទេ ប៉ុន្តែខ្ញុំពេញចិត្តនឹងក្មេងប្រុសនោះខ្លាំងណាស់។"

ពួកយើងទាំងអស់គ្នាបានចូលទៅក្នុងសណ្ឋាគារ។ "ឥលូវ" ហូលមែសបាននិយាយ "សូមអាហារបរិភោគសិន។ បន្ទាប់មកលោកអាចយកកង់មកបង្ហាញខ្ញុំក៏បាន។"

"ខ្ញុំគ្មានកង់ទេ" លោកហាយែសបានស្រដី។

ហូលមែសបានដាក់ប្រាក់មួយផោនលើតុ។

"ខ្ញុំប្រាប់លោកថាខ្ញុំគ្មានកង់ទេ! លោកអាចយកសេះពីរក្បាលដើម្បីនាំលោកទៅគេហដ្ឋានបាន។"

គាត់បានយកអាហារឲ្យពួកយើងបរិភោគ ហើយពួកយើងបានហូបយ៉ាងឃ្លាន។ តាមបង្អួច យើងអាចមើលឃើញក្រោលសេះនៅខាងក្រោយសណ្ឋាគារ។ ហូលមែសបានក្រោកឡើងមួយរំពេច ហើយដើរជុំវិញបន្ទប់ បន្ទាប់មកក៏ឈរស្ងៀម សម្លឹងមើលទៅក្រៅបង្អួចឯក្រោលសេះ។ យ៉ាងគួរឲ្យភ្ញាក់ផ្អើល ជើងរបស់គាត់មានសភាពធូរស្រាលជាងមុនហើយ។

ភ្លាមនោះគាត់ក៏ផ្ទុះសំណើច ហើយសម្លឹងមើលមកខ្ញុំ។ "ខ្ញុំយល់ហើយ!" គាត់បានស្រែក។ "ប្រាកដណាស់វាអញ្ចឹងហើយ។ វ៉ាត់សាន់ តើឯងមានឃើញដានជើងគោថ្ងៃនេះទេ?"

"មែនហើយ" ខ្ញុំបាននិយាយ។ "ច្រើនណាស់។ គ្រប់ទីកន្លែង។"

"ហើយឯងមានឃើញគោនៅលើវាលទំនាបដែររឺទេ?"

"ខ្ញុំមិនចាំទេ។" ខ្ញុំបានស្រដី។

"តើវាមិនចម្លែកទេរឺ វ៉ាត់សាន់? ដានជើងគោច្រើនណាស់ ប៉ុន្តែគ្មានគោទេរឺ? ហើយតើឯងមានចាំដានជើងទាំងនោះទេ វ៉ាត់សាន់? គាត់បានយកសៀវភៅកំណត់ត្រារបស់គាត់ចេញមក។ "មានដានជើងដូចនេះ៖

: : : : : : : : : :

ហើយជួនកាលដូចអញ្ចេះ៖

: . : . : . : . : . : . : .

ហើយជួនកាលដូចអញ្ចេះ៖

. ` . ` . ` . ` . ` . `

តើឯងមានចង់ចាំទេ វ៉ាត់សាន់?"

"ទេ គ្នាមិនចាំទេ" ខ្ញុំបាននិយាយ។ "តើវាមានន័យដូចម្ដេច ហូលមែស?"

"វាមានន័យថាវាគឺជាគោដ៏ចម្លែកមួយ វ៉ាត់សាន់! គោមិនដើរអញ្ចឹងទេ។ ឥលូវ តោះទៅខាងក្រៅយ៉ាងស្ងាត់ៗ ហើយពិនិត្យមើលជុំវិញក្រោលសេះទាំងនេះទៅមើល។"

មានសេះដែលមើលទៅដូចជានឿយហត់ពីរក្បាលនៅក្នុងក្រោលសេះ។ ហូលមែសបានសម្លឹងមើលយ៉ាងប្រុងប្រយ័ត្នឯជើងសេះមួយក្បាល ហើយបានសើច។ "មើលនំ វ៉ាត់សាន់។ ស្បែកជើងចាស់ ប៉ុន្តែក្រចកថ្មី។ អូ រឿងក្ដីចាប់ផ្ដើមកាន់តែគួរឲ្យចាប់អារម្មណ៍ឡើងគ្រប់នាទីហើយ។"

ខ្ញុំចាប់ផ្ដើមសួរហូលមែសនូវសំនួរមួយ ប៉ុន្តែភ្លាមនោះ ពួកយើងបានឮនរណាម្នាក់នៅពីក្រោយពួកយើង ហើយម្នាក់នោះគឺលោករូបេន ហាយែស។ មុខរបស់គាត់ឡើងក្រហម ហើយខឹង។

"តើលោកកំពុងតែធ្វើអ្វីក្នុងក្រោលសេះរបស់ខ្ញុំ?" គាត់បានស្រែក។

"ពួកយើងគ្រាន់តែពិនិត្យមើលសេះរបស់លោកទេតើ លោកហាយែស" ហូលមែសបានស្រដីដោយញញឹម។ "ហេតុអ្វី? តើលោកខ្លាចរឿងអីរឺ?"

បុរសនោះបានចំហមាត់របស់គាត់ បន្ទាប់មកបិទមាត់យ៉ាងរហ័ស។ មុខរបស់គាត់នៅតែក្រហមហើយខឹង។ ហូលមែសមិនបានផ្ដល់ពេលឲ្យគាត់និយាយឡើយ។

"ខ្ញុំគិតថាសេះរបស់លោកនឿយហត់ហើយ លោកហាយែស។ ពួកយើងអាចដើរទៅគេហដ្ឋាននោះបាន។ វានៅមិនឆ្ងាយទេ។"

"បីគីឡូម៉ែត បើដើរតាមផ្លូវ" លោកហាយែសបានស្រដី។ ភ្នែករបស់គាត់នៅតែមើលពួកយើងយ៉ាងខឹងសំបារ។

វាជិតព្រលប់ហើយនៅពេលដែលយើងចាកចេញទៅ។ ពួកយើងបានដើរតាមផ្លូវប្រហែលជាបានមួយរយម៉ែត។ បន្ទាប់មក ហូលមែសបានចាប់ដៃរបស់ខ្ញុំ។ "ឲ្យលឿនឡើង វ៉ាត់សាន់! ចេញពីផ្លូវ ហើយឡើងទៅ លើជ្រលងភ្នំទៅ។ បន្ទាប់មកពួកយើងអាចចុះពីលើជ្រលងភ្នំមកខាងក្រោយសណ្ឋាគារបាន។"

ពួកយើងបានរត់ឡើងលើជ្រលងភ្នំ។ "ហាយែសម្នាក់នេះ" ខ្ញុំបាននិយាយ។ "គេដឹងពីរឿងចាប់ជំរិតនេះទាំងអស់។ តើខ្ញុំនិយាយត្រូវទេ ហូលមែស?"

"ជាការពិតណាស់" គាត់បានស្រដី។ "ពួកយើងអាចស្វែងយល់បន្ថែមទៀតជាច្រើនពីលោកហាយែស។ អា! តើម្នាក់នេះជានរណា? វ៉ាត់សាន់ ចុះទៅក្រោមទៅ!"

មានកង់មួយគ្រឿងនៅលើផ្លូវ។ វាមកកាត់មុខពួកយើងយ៉ាងរហ័សជាទីបំផុត ហើយពួកយើងបានឃើញអ្នកជិះ-លោកជេមស៍ វាលដឺរ ដែលត្រូវជាលេខារបស់លោកអភិជន។ មុខរបស់គាត់ឡើងស្លេកហើយខ្លាចទៀតផង។

"ឲ្យលឿនឡើង វ៉ាត់សាន់!" ហូលមែសបាននិយាយ។ "ពួកយើងត្រូវតែតាមដានពួកគេ។"

ពួកយើងបានរត់ចុះជ្រលងភ្នំ ហើយឈប់នៅពេលដែលពួកយើងអាចមើលឃើញទ្វារខាងក្រោយសណ្ឋាគារបាន។ កង់របស់វ៉ាលដឺរនៅជិតជញ្ជាំងជាប់នឹងទ្វារ។ អស់ពេលប្រាំនាទី គ្មានអ្វីកើតឡើងនោះទេ បន្ទាប់មកមានបុរសម្នាក់ជិះសេះមួយក្បាលយ៉ាងរហ័សចេញពីក្រោលសេះ ហើយចុះទៅផ្លូវ។

"តើឯងគិតយ៉ាងណា វ៉ាត់សាន់?" ហូលមែសបានស្រដី។

"មាននរណាម្នាក់កំពុងតែរត់គេចខ្លួនហើយ។"

"មែនហើយ ប៉ុន្តែមិនមែនជេមស៍ វ៉ាលដឺរ ពីព្រោះគេនៅទីនោះជិតមាត់ទ្វារ។"

ពួកយើងអាចមើលឃើញវ៉ាលដឺរបានដោយសារពន្លឺចង្កៀងនៅលើទ្វារ។ គេឈរនៅទីនោះ សម្លឹងមើលមកខាងក្រៅ ហើយដប់នាទីក្រោយមក មានបុរសម្នាក់ទៀតដើរចេញពីផ្លូវ ហើយសំដៅទៅក្នុងសណ្ឋាគារនោះ។ បន្ទាប់មកមានភ្លើងនៅក្នុងបន្ទប់ជាន់ខាងលើ។

"មក វ៉ាត់សាន់។ ពួកយើងត្រូវតែទៅឲ្យកាន់តែជិត" ហូលមែសបាននិយាយ។

ពួកយើងបានដើរចុះជ្រលងភ្នំ ហើយដើរយ៉ាងលបៗទៅកាន់ទ្វារខាងក្រោយសណ្ឋាគារ។ កង់នៅជិតនឹងជញ្ជាំងនៅឡើយទេ។ ហូលមែសបានសម្លឹងមើលកង់ ហើយសើចយ៉ាងស្ងៀមស្ងាត់។

*"កង់ឌុនលុប វ៉ាត់សាន់! ឥលូវ គ្នាត្រូវតែមើលតាមបង្អួចជាន់ខាងលើនោះ អញ្ចឹងគ្នាត្រូវការខ្នងរបស់ឯងបន្តិច វ៉ាត់សាន់។"*

*ហូលមែសឈរលើខ្នងរបស់ខ្ញុំ ប៉ុន្តែត្រឹមតែមួយវិនាទីប៉ុណ្ណោះ ហើយបន្ទាប់មកក៏ចុះមកវិញ។ "មកសម្លាញ់" គាត់បានស្រដី។ "វាចំនាយពេលយូរណាស់ទំរាំតែដល់សាលា អញ្ចឹងឆាប់ចេញដំណើរទៅ។ គ្នាអាចប្រាប់ឯងនូវចម្លើយទាំងអស់ចំពោះអាថ៌កំបាំងនេះនៅថ្ងៃស្អែក។"*

*វាពិតជាចំនាយពេលយូរមែនទំរាំតែដល់សាលាវិញ។ ខ្ញុំបានទៅដេកភ្លាមមួយរំពេច ប៉ុន្តែហូលមែសបានចេញទៅក្រៅម្តងទៀត ខ្ញុំគិតថាប្រហែលជាទៅម៉ាកខ្ញុំតុនហើយ។ ខ្ញុំពិតជាអស់កម្លាំងណាស់ ហើយដេកពេញមួយយប់ដូចជាមនុស្សស្លាប់អញ្ចឹង។*

# វគ្គ ៦

# ការសន្ទនាគ្នាជាមួយលោកអភិជន

*នៅម៉ោងដប់មួយព្រឹកបន្ទាប់ ហូលមែស និងខ្ញុំស្ថិតនៅក្នុងការិយាល័យរបស់លោកអភិជននៅគេហដ្ឋានហូលដឺនែស។ លោកវ៉ាលដឺរបានចូលមកនិយាយជាមួយពួកយើង។*

*"លោកអភិជនមិនទទួលភ្ញៀវទេនៅថ្ងៃនេះ" គេបាននិយាយជាហូលមែស។*

*ហូលមែសសម្លឹងមើលគេយ៉ាងសោះកក្រោះ។ "លោកអភិជនអាចជួបខ្ញុំបាន" គាត់បានស្រដី។ "សូមប្រាប់គាត់ថាខ្ញុំនៅទីនេះទៅ។"*

*កន្លះម៉ោងក្រោយមក លោកអភិជននៃហូលដឺនែសបានចូលមកក្នុងបន្ទប់។ គាត់មើលទៅដូចជាចាស់ជាងមុខ-នឿយហត់ ហើយមិនសូវស្រួលខ្លួន។*

*"សួស្តីលោកហូលមែស" គាត់បាននិយាយ។*

*ហូលមែសសម្លឹងមើលលោកជេមស៍ វ៉ាលដឺរ។ "ខ្ញុំអាចនិយាយស្រួលជាងប្រសិនបើគ្មានលេខារបស់លោកនៅទីនេះ។"*

*"ល្អណាស់" លោកអភិជនបានស្រដីយ៉ាងនឿយហត់។ "សូមចេញក្រៅទៅ ជេមស៍..."*

*ជេមស៍វ៉ាលដឺបានសម្លឹងមើលមុខហូលមែសយ៉ាងខឹងសំបារ ប៉ុន្តែគេនៅតែចាកចេញពីបន្ទប់ ហើយបិទទ្វារយ៉ាងខ្លាំង។*

ហូលមែសសម្លឹងមើលលោកអភិជន។ "ខ្ញុំឮថាលោកនឹងឲ្យប្រាក់ប្រាំពាន់ផោនសម្រាប់ដំណឹងអំពីកូនប្រុសរបស់លោក។"

"នេះជាការពិត។"

"ហើយប្រាក់មួយពាន់ផោនទៀតសម្រាប់ឈ្មោះអ្នកចាប់ជំរិត។

"ពិតហើយ។"

មិត្តរបស់ខ្ញុំញញឹម។ "ខ្ញុំបាទបានឃើញសៀវភៅសែករបស់លោកនៅលើតុហើយ លោក។ ខ្ញុំចង់បានសែកប្រាក់ប្រាំមួយពាន់ផោនរបស់លោក។"

"លោកស្ស៊ឺឡក់ ហូលមែស" លោកអភិជនបានស្រដីយ៉ាងខឹងសំបារ "តើលោកចង់និយាយពីអ្វី? តើលោកមានដំណឹងពីកូនប្រុសខ្ញុំដែររឺទេ?"

"អូ បាទ" ហូលមែសបាននិយាយ។

ភ្នែករបស់លោកអភិជនមិនដែលគ្រលៀសចេញពីហូលមែសបន្តិចឡើយ។ "តើកូនរបស់ខ្ញុំនៅឯណា?" គាត់បាននិយាយយ៉ាងស្ងាត់ៗ។

"ឥលូវគេនៅ-រឺក៏កាលពីយប់មុន-ឯសណ្ឋាគារហ្វ្រីនមែន បីគីឡូម៉ែតតាមផ្លូវទៅឆេសតឺហ្វៀល។"

លោកអភិជនដួលទៅលើកៅអីរបស់គាត់។

"ហើយឈ្មោះអ្នកចាប់ជំរិត?"

ចម្លើយរបស់ស្ស៊ឺឡក់ ហូលមែសគឺពិតជាគួរឲ្យភ្ញាក់ផ្អើលមែនទែន។ "គឺលោក" គាត់បាននិយាយ។ "ហើយឥលូវ ខ្ញុំសូមយកសែករបស់លោក។"

លោកអភិជនបានក្រោកឈរឡើង មុខរបស់គាត់ឡើងស្លេកស្លាំង ហើយខឹងយ៉ាងខ្លាំង។ បន្ទាប់មកគាត់អង្គុយចុះម្តងទៀត ហើយយកដៃខ្ទប់មុខរបស់គាត់។ វាចំនាយពេលដល់ទៅពីរបីនាទីមុននឹងគាត់ផ្តើមនិយាយ។

"តើលោកដឹងច្រើនប៉ុណ្ណា?" គាត់បានសួរ។

"ខ្ញុំឃើញលោកនៅជាមួយគេកាលពីម្សិលមិញ។" ហូលមែសបាននិយាយ។

"ហើយតើមានមនុស្សប៉ុន្មាននាក់ដឹងពីរឿងនេះ?"

"មានតែខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំវ៉ាត់សាន់តែប៉ុណ្ណោះ។"

លោកអភិជនយកប៊ិចរបស់គាត់ចេញមក បើកសៀវភៅសែករបស់គាត់ ហើយចាប់ផ្ដើមសរសេរ។ "នៅពេលដែលខ្ញុំបង្កើតនូវសម្បទាននេះ ខ្ញុំមិនបានដឹងថា..." គាត់បានឈរ បន្ទាប់មកក៏ចាប់ផ្ដើមនិយាយម្ដងទៀត។ "តើលោក និងមិត្តភក្ដិរបស់លោកនឹងយករឿងនេះទៅនិយាយប្រាប់គេទេ លោកហូលមែស?"

"ខ្ញុំមិនយល់លោកនិយាយទេ" ហូលមែសបានស្រដី។

"ខ្ញុំចង់មានន័យថា...គ្មាននរណាម្នាក់ត្រូវដឹងបញ្ហាគ្រួសារបន្តិចបន្តួចនេះឡើយ។ មានតែលោក និងមិត្តភក្ដិរបស់លោកតែប៉ុណ្ណោះ។ មើលចុះ នេះគឺជាសែករបស់ខ្ញុំសម្រាប់ប្រាក់ដប់ពីរពាន់ផោន។"

ហូលមែសញញឹមដោយសោះកក្រោះ។ "ខ្ញុំសូមទោស លោក។ មានមនុស្សស្លាប់ក្នុងរឿងក្ដីនេះ។ លោកមានចាំទេ?"

"ប៉ុន្តែជេមស៍មិនមែនជាឃាតករទេ!" លោកអភិជនបានស្រែក។ "គេមិនដឹងរឿងនេះទេ។ គេពិតជាមិនសប្បាយចិត្តទាល់តែសោះនៅពេលដែលគេឮដំណឹងអំពីឃាតកម្មនោះ។"

"ឃាតកម្ម" ហូលមែសបាននិយាយ។

"ប៉ុន្តែជេមស៍មិននៅទីនោះទេ! ហើយនៅពេលដែលគេឮដំណឹងនោះ គេមកជួបខ្ញុំមួយរំពេច ហើយប្រាប់ខ្ញុំនូវអ្វីៗគ្រប់យ៉ាង។ អូ លោកហូលមែស លោកត្រូវតែជួយខ្ញុំផង! គេមិនមែនជាឃាតករទេ! ឃាតករបានរត់គេចកាលពីយប់មិញទៅហើយ។"

ហូលមែសញញឹមម្ដងទៀត។ "ខ្ញុំមានដំណឹងសម្រាប់លោកថែមទៀត។ ប៉ូលីសបានជួបលោករូបេន ហាយែសកាលពីយប់មិញនៅឯស្ថានីយ៍ឆេសតឺហ្វៀល។ លោកហាយែសនឹងរត់គេចមិនរួចឡើយ។"

លោកអភិជនសម្លឹងមើលហូលមែសដោយចំហមាត់ផ្ទុង។ "លោក...លោកដឹងអ្វីៗគ្រប់យ៉ាងអស់ហើយ!" គាត់បាននិយាយ។ "ប៉ុន្តែខ្ញុំរីករាយណាស់ដែលទទួលបានដំណឹងចំពោះហាយែស-គេតែងតែជាមនុស្សអាក្រក់ជានិច្ច។ ហើយដំណឹងនោះអាចជួយជេមស៍បាន។"

"ជេមស៍? លេខារបស់លោករឺ?" ហូលមែសបានស្រដី។

"ទេ លោក។ កូនប្រុសរបស់ខ្ញុំ។ ជេមស៍ វ៉ាលដឺរគឺជាកូនប្រុសរបស់ខ្ញុំ។"

# វគ្គ ៧

# កូនប្រុសរបស់លោកអភិជន

*នៅពេលដែលលោកអភិជននិយាយដូចនេះ ខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ ប៉ុន្តែហូលមែសក៏ភ្ញាក់ផ្អើលដែរ។*

*"នេះគឺជាជំនឹងសម្រាប់ខ្ញុំ" គាត់បានស្រដី។ "តើលោកអាចប្រាប់ខ្ញុំបន្ថែមទៀតបានទេ?"*

*លោកអភិជនបានក្រោកឈរឡើង ហើយដើរជុំវិញបន្ទប់ប្រហែលជាមួយនាទី។ "ខ្ញុំត្រូវតែប្រាប់រឿងនូវអ្វីៗគ្រប់យ៉ាង" គាត់បាននិយាយ។ "ខ្ញុំមិនចង់និយាយអំពីវានោះទេ ប៉ុន្តែខ្ញុំត្រូវតែនិយាយ។ ខ្ញុំយល់រឿងនោះហើយឥលូវ។"*

*គាត់បានអង្គុយចុះម្តងទៀត ហើយចាប់ផ្តើមនិយាយរឿងរបស់គាត់។ "នៅពេលដែលខ្ញុំនៅក្មេង លោកហូលមែស ខ្ញុំមានស្នេហា-អូ ពិតជាមានស្នេហាខ្លាំងណាស់។ វាទើបតែកើតឡើងចំពោះលោកតែម្តងគត់ ហើយស្ត្រីម្នាក់នេះគឺជាស្ត្រីដែលខ្ញុំស្រលាញ់បំផុតក្នុងមួយជីវិត។ ខ្ញុំចង់ឲ្យនាងធ្វើជាប្រពន្ធរបស់ខ្ញុំ-ប៉ុន្តែនាងស្លាប់បាត់ទៅហើយ។ នាងបានទុកកូនប្រុសម្នាក់ឲ្យខ្ញុំ ហើយខ្ញុំស្រលាញ់គេដោយសារតែនាង។ នៅពេលដែលខ្ញុំសម្លឹងមើលមុខរបស់គេ ក៏ដូចជាខ្ញុំសម្លឹងមើលនាងអញ្ចឹងដែរ ហើយចងចាំនាង ព្រមទាំងមិនអាចឈប់ស្រលាញ់នាងបានឡើយ។ ខ្ញុំត្រូវតែមានក្មេងប្រុសនោះនៅជិតខ្លួនខ្ញុំដោយសារតែរឿងនេះ។ ប៉ុន្តែមន្ត្រីរាជការមិនអាចប្រាប់ពិភពលោកឲ្យដឹងពីកូនដ៏គួរឲ្យស្រលាញ់ម្នាក់ដូចនេះឡើយ។ អញ្ចឹង ចំពោះពិភពលោក ជេមស៍គឺជាលេខាវ័យក្មេងរបស់ខ្ញុំ មិនមែនជាកូនរបស់ខ្ញុំឡើយ។*

"គេដឹងថាខ្ញុំជាឪពុករបស់គេ។ គេស្អប់អ្នកស្រីអភិជន ពីព្រោះនាងមិនមែនជាម្ដាយរបស់គេ។ ហើយគេស្អប់ប្អូនប្រុសចុងរបស់វា អស់សឺ ដោយសារតែអស់សឺមានអ្វីៗគ្រប់យ៉ាង។ អស់សឺមានឈ្មោះ មានឪពុកដ៏ល្បីល្បាញម្នាក់ ប្រាក់ អ្វីៗគ្រប់យ៉ាង។ ជេមស៍គ្មានអ្វីឡើយ។ ជាការពិតណាស់ គេមានប្រាក់មួយចំនួន ប៉ុន្តែគេគ្រាន់តែជាជេមស៍ វ៉ាលដឺរប៉ុណ្ណោះ ហើយគេចង់ធ្វើជាអភិជននៃហូលដឺនែសនៅថ្ងៃណាមួយ។ វាមិនអាចទៅរួចទេ ជាការពិតណាស់ ប៉ុន្តែជេមស៍មិនយល់រឿងនោះឡើយ។ ហើយអញ្ចឹង ដូចដែលលោកឃើញស្រាប់ហើយ ខ្ញុំខ្លាចជំនួសអស់សឺ ហើយនោះគឺជាមូលហេតុដែលខ្ញុំបញ្ជូនគេឲ្យទៅរៀននៅសាលារបស់លោកវេជ្ជបណ្ឌិតហ៊ុកស៍ថាបល។

"ហើយតើជេមស៍ធ្វើអ្វីបន្ទាប់មកទៀត? គេបានចាប់ជំរិតអស់សឺកំសត់របស់ខ្ញុំ។ វាគ្មានផ្លាស់ប្ដូរអ្វីឡើយ ប៉ុន្តែជេមស៍មិនយល់ឃើញអញ្ចឹងទេ។ គេចង់ឲ្យខ្ញុំប្រាប់គេថា "មែនហើយ ជេមស៍ ឥលូវឯងអាចក្លាយជាកូនប្រុសទីមួយរបស់ពុកហើយ ឯងអាចមានអ្វីៗគ្រប់យ៉ាងបាន។ អស់សឺអាចជាកូនទីពីរ។" ប៉ុន្តែខ្ញុំមិនអាចធ្វើដូច្នោះបានឡើយ ជាការពិតណាស់ខ្ញុំមិនអាចធ្វើបានទេ។

"ជេមស៍ស្គាល់ហាយេសម្នាក់នេះ លោកដឹងស្រាប់ហើយ ដោយសារហាយេសធ្លាប់ធ្វើការឲ្យខ្ញុំម្ដង។ ជេមស៍ទៅសុំជំនួយពីហាយេស ហើយបុរសនោះក៏យល់ស្របតាម។ តើលោកមានចាំសំបុត្រដែលខ្ញុំផ្ញើទៅអស់សឺនៅថ្ងៃចុងក្រោយនោះទេ? មែនហើយ ជេមស៍បានបើកសំបុត្រនោះ ហើយទុកសារមួយសម្រាប់គេ។ នៅល្ងាចនោះ គេបានជិះកង់កាត់តាមវាលទំនាប ហើយជួបអស់សឺនៅរេកស៊ិរ។ គេបានពិភាក្សាគ្នាអំពីអ្នកស្រីអភិជន ដែលត្រូវជាម្ដាយរបស់អស់សឺ។ "គេចង់ជួបឯង។" គេបានប្រាប់អស់សឺ។ "គេកំពុងរង់ចាំឯងនៅឯវាលទំនាបឯណោះ។ ត្រលប់មកវិញនៅពាក់កណ្ដាលអធ្រាត្រមក ហើយបុរសម្នាក់នឹងជិះសេះនាំឯងទៅជួបគេ។" ជាការពិតណាស់ អស់សឺកំសត់ចង់ជួបម្ដាយរបស់គេ អញ្ចឹងគេក៏មកតាមពាក្យសន្យា។ ហាយេសនៅទីនោះជាមួយនឹងសេះពីរក្បាល ហើយពួកគេបានជិះសេះឆ្លងកាត់វាលទំនាប។ ប៉ុន្តែគ្រូបង្រៀនជនជាតិអាល្លឺម៉ង់បានដេញតាមពួកគេ ហើយហាយេសក៏សម្លាប់គេចោលទៅ។ បន្ទាប់មក ហាយេសបាននាំអស់សឺទៅសណ្ឋាគារហ្គ្រីនមែន។"

"មែនហើយ លោកហូលមែស ខ្ញុំគ្មានដឹងរឿងនេះបន្តិចទេ-រហូតដល់មានឃាតកម្ម។ ជេមស៍ជាក្មេងអាក្រក់ ប៉ុន្តែគេមិនធ្វើឃាតមនុស្សឡើយ។ នៅពេលដែលគេឮដំណឹងនេះ គេបានមកជួបខ្ញុំភ្លាមមួយរំពេច ដោយទ្រហ៊ោយំ។ តើខ្ញុំអាចធ្វើអ្វីបាន? ខ្ញុំមិនចង់ឲ្យពិភពលោកទាំងមូលដឹងរឿងនេះឡើយ។ អញ្ចឹងជេមស៍បានចុះទៅហ្គ្រីនមែន។ គេបានប្រាប់ហាយេសឲ្យរត់គេច ពីព្រោះឥលូវអ្នកពល់គ្នាដឹងអំពី

ឃាតកម្មអស់ហើយ-ហើយក៏ស្គាល់ឈ្មោះឃាតករដែរ។ ហាយែសបានចាកចេញភ្លាមមួយរំពេច។ ក្រោយមក ខ្ញុំបានចុះទៅ ហើយឃើញអស់សឺ។ ខ្ញុំបានទុកគេនៅទីនោះជាមួយនឹងអ្នកស្រីហាយែសពីព្រោះខ្ញុំមិនអាចនិយាយប្រាប់ប៉ូលីសបានទេ។

"អញ្ចឹង លោកហូលមែស ឥលូវលោកដឹងរឿងទាំងមូលហើយ។"

"អ៊ឹម" ហូលមែសបាននិយាយ។ "លោកជួយឃាតករម្នាក់ លោកមិននិយាយអ្វីមួយម៉ាត់ប្រាប់ប៉ូលីស លោកទុកកូនប្រុសវ័យក្មេងរបស់លោកនៅក្នុងសណ្ឋាគារគគ្រិច...ហើយលោកសុំជំនួយពីខ្ញុំ។"

ជាធម្មតា គ្មានមនុស្សណាហ៊ាននិយាយនិយាយជាមួយលោកអភិជននៃហូលដឺនែសដូចនេះឡើយ។ មុខរបស់គាត់ឡើងក្រហម ប៉ុន្តែគាត់មិននិយាយអ្វីឡើយ។

"មុនដំបូង" ហូលមែសបានស្រដី "យើងត្រូវតែនាំអស់សឺមកផ្ទះវិញ។"

"មែនហើយ" លោកអភិជននិយាយយ៉ាងស្ងាត់ៗ។

ហូលមែសបានសរសេរសារមួយយ៉ាងរហ័ស ហើយយកវាចេញពីបន្ទប់។ មួយនាទីក្រោយមកគាត់ក៏ត្រលប់មកវិញ។ "ឥលូវ តើលោកនឹងធ្វើអ្វីអំពីលោកជេមស៍ វ៉ាលដឺរ?" គាត់បាននិយាយ។

"ខ្ញុំយល់ហើយ លោកហូលមែស" លោកអភិជនបានស្រដី។ "ជេមស៍នឹងចាកចេញពីខ្ញុំ ហើយទៅប្រទេសអូស្ត្រាលីនៅសប្តាហ៍ក្រោយ។"

"ល្អ" ហូលមែសបាននិយាយ។ "ហើយចុះចំនែកអ្នកស្រីអភិជនវិញ? ប្រហែលជាគ្មានជេមស៍នៅក្នុងផ្ទះទេ លោក និងនាង..."

"មែនហើយ។ ខ្ញុំបានសរសេរសំបុត្រផ្ញើទៅអ្នកស្រីអភិជននៅព្រឹកនេះហើយ។"

ហូលមែសបានក្រោកឈរឡើង។ "ល្អ" គាត់បានស្រដី។ "ខ្ញុំគិតថាវ៉ាត់សាន់ និងខ្ញុំអាចទៅផ្ទះបានហើយឥលូវ។ វាមានតែរឿងបន្តិចបន្តួចមួយទៀតតែប៉ុណ្ណោះ...ហាយែសម្នាក់នេះបានយកសេះពីរក្បាលទៅវាលទំនាប ប៉ុន្តែជើងរបស់សេះទាំងនោះបែរជាធ្វើឲ្យមានដានជើងគោនៅលើកក់ទៅវិញ។ តើវាអាចទៅរួចយ៉ាងម៉េចទៅ?"

លោកអភិជនមើលទៅដូចជាភ្ញាក់ផ្អើល ហើយគិតអស់មួយស្របក់។ បន្ទាប់មកគាត់បានចេញទៅក្រៅ ហើយត្រលប់មកវិញជាមួយនឹងប្រអប់កញ្ចក់មួយនៅក្នុងដៃរបស់គាត់។ នៅក្នុងប្រអប់នោះមានស្បែកជើងសេះមួយចំនួន។

"ពួកយើងបានរកឃើញស្បែកជើងទាំងនេះនៅក្រោមដីក្នុងសួនច្បារ" លោកអភិជនបានស្រដី។ "ពួកយើងគិតថាពួកវាមានអាយុកាលប្រហែលជាប្រាំរយឆ្នាំមកហើយ។ គ្រួសារហូលដឺនៃសមានរឿងអតីតកាលដ៏វែងឆ្ងាយ និងគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់។"

ហូលមែសបានបើកប្រអប់ ហើយយកស្បែកជើងមួយចេញមក។ វាជាស្បែកជើងសម្រាប់ពាក់ជើងសេះ ប៉ុន្តែវាមើលទៅដូចជាជើងគោដែលបែកជាពីរអញ្ចឹង។ ហូលមែសផ្ទើមម្រាមដៃរបស់គាត់ហើយអូសវាជុំវិញបាតស្បែកជើង។ មានកក់បន្តិចបន្តួចចេញពីម្រាមដៃរបស់គាត់។

"អរគុណលោកហើយ" ហូលមែសបាននិយាយ។ គាត់បានទុកស្បែកជើងសេះក្នុងប្រអប់វាវិញ។ "ស្បែកជើងនោះគឺជារឿងទីពីរដ៏គួរឲ្យចាប់អារម្មណ៍បំផុតនៅទិសខាងជើងប្រទេសអង់គ្លេស" គាត់បានស្រដី។

"ហើយចុះរឿងទីមួយវិញ?" លោកអភិជនបានសួរ។

ហូលមែសយកសែកប្រាក់ដប់ពីរពាន់ផោនពីលើតុ ហើយទុកវានៅក្នុងសៀវភៅកំណត់ត្រារបស់គាត់យ៉ាងយឺតៗ។ "ខ្ញុំគឺជាមនុស្សក្រីក្រម្នាក់" គាត់បាននិយាយ។ គាត់សម្លឹងមើលយ៉ាងគួរឲ្យស្រលាញ់ឯសៀវភៅកំណត់ត្រារបស់គាត់ បន្ទាប់មកដាក់វាយ៉ាងប្រុងប្រយ័ត្នក្នុងហោប៉ៅរបស់គាត់។